អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩

## សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបញ្ចប់សវនាការរយៈពេលបីថ្ងៃនៅក្នុងសំណុំរឿង ០០៤/២

នៅថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ចប់សវនាការរយៈពេលបីថ្ងៃនៅក្នុងសំណុំរឿង ០០៤/២ ប្រឆាំងនឹង អោ អាន។ សហព្រះរាជអាជ្ញាអន្តរជាតិ សហព្រះរាជអាជ្ញារងជាតិ និងសហមេធាវីការពារក្តីជាតិ-អន្តរជាតិ បានបង្ហាញទឡ្ហីករណ៍របស់ខ្លួននៅក្នុងសំណុំរឿងនេះ។ អោ អាន បានផ្តល់ជូនអង្គបុរេជំនុំជម្រះនូវលិខិតបញ្ជាក់សុខភាពដែលបញ្ជាក់ថា ដោយសារមូលហេតុសុខភាព គាត់មិនមានកាយសម្បទាគ្រប់គ្រាន់អាចធ្វើដំណើរផ្លូវឆ្ងាយមកតុលាការបានឡើយ។ គាត់មានសហមេធាវីតំណាងគាត់នៅក្នុងសវនាការនេះ។

អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ បណ្តឹងឧទ្ធរណ៍ដាក់ដោយសហមេធាវីតំណាង អោ អាន នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៤/២ និងបណ្តឹងឧទ្ធរណ៍ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់ជនត្រូវចោទដែលចេញដោយសហចៅក្រមស៊ើបអង្កេតជាតិនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ នៅក្នុងសំណុំរឿង ០០៤/២។

តាងនាមឲ្យអង្គបុរេជំនុំជម្រះទាំងមូល មានការចេញរបាយការណ៍មួយរួចហើយអំពីសំណុំរឿងនេះដែលបង្ហាញអំពីអង្គហេតុ និងប្រវត្តិនីតិវិធីពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៤/២ ព្រមទាំងសេចក្តីលម្អិតនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ សំណៅជាសាធារណៈដោយមានការកោសលុបនៃរបាយការណ៍នេះអាចរកមើលបានតាមរយៈគេហទំព័រ៖

https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D359_7_Redacted_KH.PDF
https://www.eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D360_16_Redacted_KH.PDF

អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចថាតើ អោ អាន ត្រូវតាមលក្ខខណ្ឌតម្រូវនៃយុត្តាធិការរបស់តុលាការដែរឬអត់ និងថាតើមានបទចោទគ្រប់គ្រាន់ដើម្បីបញ្ជូនគាត់ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មតាមការចោទប្រកាន់ ឬក៏ការ

ចោទប្រកាន់ប្រឆាំងនឹងគាត់នឹងត្រូវលើកលែងចោទ។ សម្រាប់ពេលឥឡូវនេះ អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណា ដើម្បីចេញសាលដីកាសម្រេច។ សាលដីកាសម្រេចនេះគឺជាសាលដីកាស្ថាពរមិនមានបណ្តឹងឧទ្ធរណ៍បន្ថែមទៀតទេ៕

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥(0)១២៤៨៨១៥៦
ទូរស័ព្ទលើតុ: +៨៥៥(0)២៣៨៦១៥៦៤
អ៊ីម៉ែល: neth.pheaktra@eccc.gov.kh